# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អតិបូជាខួប១០ឆ្នាំនៃក្រុមបេះដូងព្រះយេស៊ូនៅកម្ពុជា
# ចំប៉ាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨
*រស់នៅជាសាក្សីនៃសេចក្តីស្រឡាញ់*

អត្ថបទទី១៖ វវ ៧,២+៤.៩-១៤
អត្ថបទទី២៖ ១យហ ៣,១-៣
ដំណឹងល្អ៖ មថ ៥,១-១២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងគោរពសន្តបុគ្គលទាំងឡាយ យើងមានអំណរសប្បាយដោយអរព្រះគុណព្រះជាម្ចាស់ សម្រាប់១០ឆ្នាំនៃក្រុមបេះដូងព្រះយេស៊ូ នៅព្រះសហគមន៍កម្ពុជា។ ល្មមដល់ពេលយើងដើរខ្លួនយើង ដោយមានបងរបស់យើងនៅប្រទេសវៀតណាម ឧទាហរណ៍ប៉ុន្មានឆ្នាំមុនខ្ញុំសុំលោកឪពុកទីនឲ្យយើងរៀនធ្វើស្ករគ្រាប់ដូងនៅវៀតណាមគេពូកែធ្វើ ដូច្នេះលោកឪពុកទីនគាត់បានទៅអញ្ជើញគ្រួសារកាតូលិកមកពីវៀតណាមមួយ ដើម្បីមកបង្រៀនជនពិការដែលនៅផ្ទះខ្ញុំអំពីរបៀបធ្វើស្ករគ្រាប់នោះ។ ថ្ងៃនេះ ខ្ញុំមិនសរសេរស្ករគ្រាប់ដូងវៀតណាម ប៉ុន្តែជាស្ករគ្រាប់ដូងដែលផលិតនៅប្រទេសកម្ពុជា។ ប៉ុន្មានថ្ងៃមុន ខ្ញុំបានបញ្ជូនសិស្សបច្ចេកទេសកសិកម្មដែលទើបនឹងប្រឡងជាប់ ទៅរៀនដាំផ្កានៅទីក្រុងដាឡាតប្រទេសវៀតណាម ពេលពួកគេត្រឡប់មកវិញខ្ញុំនឹងរៀបចំកន្លែងដើម្បីដាំផ្កាតាម និងក្រោយមកនេះជាផ្កាដែលដាំនៅប្រទេសកម្ពុជា អ្នកដែលបង្រៀនយើងគឺវៀតណាម។ ដូចគ្នាដែរ ក្រុមបេះដូងព្រះយេស៊ូយើងលែងជាក្រុមបេះដូងព្រះយេស៊ូវៀតណាម តែយើងជាក្រុមបេះដូងព្រះយេស៊ូកម្ពុជា ប៉ុន្តែយើងមានការសហការគ្នាដែលណែនាំឲ្យព្រះសហគមន៍របស់យើង ជាមហាគ្រួសារតែមួយ។

ថ្ងៃនេះយើងមានសន្តសន្តីបុគ្គលដែលនៅស្ថានបរមសុខ ដែលកំពុងសម្លឹងមើលយើងធ្លាប់អធិដ្ឋាននៅក្នុងធម៌ប្រកាសជំនឿថា "**សហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ**" នេះជាព្រះសហគមន៍ពិតមែន។ យើងជាមហាគ្រួសារតែមួយ ដែលចេះជួយគ្នាទៅវិញទៅមកដើម្បីឲ្យកន្លែងនីមួយៗយើងមានកម្លាំង យើងមានសមត្ថភាពដើម្បីដើរខ្លួនឯង។ យើងជាក្រុមបេះដូងព្រះយេស៊ូ យើងជាគ្រីស្តបរិស័ទ គោលដៅនៃជីវិតរបស់យើងគឺទៅជាអ្នកដ៏វិសុទ្ធ ឆ្លងភាពដ៏វិសុទ្ធពីព្រះជាម្ចាស់ដើម្បីឲ្យយើងទៅជាប្រជារាស្ត្រព្រះជាម្ចាស់យ៉ាងពិតប្រាកដ ដែលសម្តែងធម៌មេត្តាករុណាដល់បងប្អូនឯទៀងៗ។ ដូច្នេះថ្ងៃនេះ ខ្ញុំចង់ឲ្យយើងយកចិត្តទុកដាក់អ្វីដែលសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានសរសេរជូនដល់គ្រីស្តបរិស័ទទាំងអស់ អំពីផ្លូវដើម្បីឲ្យយើងជាគ្រីស្តបរិស័ទ អាចទៅជាអ្នកដ៏វិសុទ្ធដូចព្រះជាម្ចាស់។ ផ្លូវនៃភាពដ៏វិសុទ្ធ ជាអ្វីដែលយើងបានស្តាប់ក្នុងគម្ពីរដំណឹងល្អ គឺផ្លូវនៃសុភមង្គល។ មុនគេបង្អស់យើងធ្វើដូចម្តេច ដើម្បីដាក់ចិត្តជាអ្នកក្រខ្សត់ មានន័យថាសុខចិត្តលះបង់ចោល

ល។ សម្រាប់បងប្អូនដែលជាសមាជិកក្រុមបេះដូងព្រះយេស៊ូ បានលះបង់ចោលពេលវេលាផ្ទាល់ខ្លួនដើម្បីអធិដ្ឋាន ដើម្បីបង្ហាញធម៌មេត្តាករុណា ដើម្បីរស់នៅយ៉ាងជិតស្និទ្ធជាមួយព្រះសហគមន៍ និងរស់នៅជាសាក្សីនៃសេចក្តីស្រឡាញ់នៅក្នុងក្រុមគ្រួសារផង។

**ចំណុចទីមួយ** ដែលសម្តេចប៉ាបបានរំឭកឲ្យយើងដើម្បីដើរតាមផ្លូវនៃសុភមង្គល គឺឲ្យយើងមានចិត្តតស៊ូនៅក្នុងជីវិត។ ជីវិតរបស់យើងមានទុក្ខលំបាកច្រើន យើងមានបញ្ហាច្រើន ការតស៊ូជាផ្លូវទីមួយមានន័យថាលីឈើឆ្កាងដើម្បីទៅមុខជាមួយព្រះយេស៊ូ។

**ចំណុចទីពីរ** ឲ្យយើងមានចិត្តអត់ធ្មត់ ដែលចេះទន្ទឹងរង់ចាំ យើងមិនអាចទទួលអ្វីៗទាំងអស់ភ្លាមៗទេ ជួនកាលយើងអស់កម្លាំង យើងខ្ជិល ប៉ុន្តែឲ្យយើងមានចិត្តអត់ធ្មត់។ ដោយសារយើងដឹងថា នៅពេលយើងទូលអង្វរព្រះជាម្ចាស់ ព្រះអង្គនឹងប្រទានឲ្យ។ ចិត្តអត់ធម្មត់ជាមួយបងប្អូនឯទៀតៗ ចិត្តអត់ធ្មត់នៅក្នុងជីវិតរបស់យើងប្រចាំថ្ងៃ ដើម្បីទៅមុខនៅក្នុងគោលដៅរបស់យើង ខ្ញុំធ្វើយ៉ាងម៉េច ដើម្បីឲ្យព្រះជាម្ចាស់ពេញចិត្តនឹងខ្ញុំ។ អ្នកដែលក្លាយទៅជាសន្តសន្តីមិនមែនជាមនុស្សដែលពិសេសបំផុត ប៉ុន្តែមនុស្សធម្មតាក៏អាចក្លាយទៅជាសន្តសន្តីបានដែរ ដោយសារគេចេះតស៊ូ គេមានចិត្តអត់ធ្មត់ ដើម្បីយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យព្រះយេស៊ូ។

**ចំណុចទីបី** អ្នកដែលដើរតាមព្រះយេស៊ូមានអំណរសប្បាយ ពេលយើងនឹកឃើញដល់ព្រះម៉ារី សន្តសន្តីនានា ពួកគេមានអំណរសប្បាយ។ អ្នកដែលដើរតាមព្រះជាម្ចាស់មានអំណរសប្បាយ បើគ្រីស្តបរិស័ទជាមនុស្សម្នាក់ដែលចេះតែអន់ចិត្ត រករឿង ប្រហែលយើងនភឆ្ងាយពីព្រះជាម្ចាស់។ យើងដឹងហើយថា ផ្លែងនៃព្រះវិញ្ញាណដ៏វិសុទ្ធគឺអំណរសប្បាយ ដើម្បីការពារថែរក្សាអំណរសប្បាយហ្នឹង គឺឲ្យយើងសម្លឹងមើលព្រះយេស៊ូទៅ ដោយសារព្រះអង្គមានព្រះបន្ទូលថា "**ខ្ញុំចង់ឲ្យបងប្អូនមានអំណរសប្បាយ អំណរសប្បាយដ៏ពេញលក្ខណៈដែលខ្ញុំប្រទានឲ្យ**"។

**ចំណុចទីបួន** ឲ្យយើងមានសេចក្តីក្លាហាន កុំឲ្យយើងភ័យខ្លាច នៅក្នុងជីវិតរបស់យើងបានតស៊ូច្រើននិងមានភាពភ័យខ្លាចដែរ។ ក្រុមបេះដូងព្រះយេស៊ូ មានតួនាទីមួយណែនាំឲ្យសេចក្តីស្រឡាញ់ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ទៅដល់អ្នកក្រីក្រ ទៅដល់អ្នកជំងឺ ទៅដល់អ្នកដែលគ្មានទីពឹង។ ឲ្យយើងចេញពីកន្លែងចង្អៀតរបស់យើង ដើម្បីទៅមើលបងប្អូនឯទៀតៗ ដូចនៅសំប៉ានដែលជាគំរូមួយដែលមានកូនខ្មែរយ៉ាងច្រើន ដែលមករៀននៅសាលារបស់ព្រះសហគមន៍ ពេលមានកម្មវិធីចែកអំណោយ ឬកម្មវិធីផ្សេងៗព្រះសហគមន៍បានសហការជាមួយខ្មែរយ៉ាងល្អបំផុត។ ដូច្នេះ យើងត្រូវតែមានសេចក្តីក្លាហានដើម្បីឈ្នះឧបសគ្គ ឈ្នះបុរេវិនិច្ឆ័យ ដែលគិតថាវៀតណាម-ខ្មែរចូលគ្នាមិនបាន តាមពិតខ្មែរនិងវៀតណាម អាចចូលជាមួយគ្នានៅក្នុងការសិក្សាការអភិវឌ្ឍមនុស្ស និងនៅក្នុងធម៌មេត្តាករុណា។

**ចំណុចទីប្រាំ** ឲ្យយើងយកចិត្តទុកដាក់រស់នៅនៅក្នុងព្រះសហគមន៍ យើងជាក្រុមគ្រួសារតែមួយនៅក្នុងព្រះសហគមន៍ ខ្ញុំសូមរំឭកដល់លោកឪពុក បងប្រុស បងស្រី ធ្វើដូចម្ដេចដើម្បីឲ្យព្រះសហគមន៍ខាងទន្លេបាសាក់និងខាងទន្លេមេគង្គទៅជាអង្គតែមួយ ជាមួយភូមិភាគភ្នំពេញទាំងមូល។ កុំឲ្យបងប្រុសបងស្រីចេះតែប្រើភាសាវៀតណាមរហូត ដែលណែនាំឲ្យកូនក្មេងលេងចូលយ៉ាងសកម្មនៅក្នុងសកម្មភាពភូមិភាគទាំងមូល ដោយសារយុវជនមួយចំនួនធំឥតចេះនិយាយភាសាខ្មែរ។ យើងមានកម្មវិធីអក្ខរកម្ម និងបឋមសិក្សាជាង២០ឆ្នាំមកហើយ ល្មមឲ្យយុវជនចេះនិយាយភាសាខ្មែរយ៉ាងច្បាស់ ដើម្បីចូលរួមនៅក្នុងព្រះសហគមន៍កម្ពុជាដែលជាម្ចាស់ទឹកម្ចាស់ដី។

**ចំណុចទីប្រាំមួយ** អធិដ្ឋានជានិច្ចនេះជាដើម នេះជាចុងអធិដ្ឋានជានិច្ចដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់។ ក្រុមបេះដូងព្រះយេស៊ូ និងក្រុមលេហ្សុងម៉ារី បានចូលព្រះវិហារច្រើនជាគេ គេសូត្រផ្ដាំ អធិដ្ឋានជារៀងរាល់ថ្ងៃដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់។ ខ្ញុំអញ្ជើញបងប្អូនឲ្យថែរក្សារបៀបនេះ ជាគំរូសម្រាប់បងប្អូនឯទៀតៗដែលចូលព្រះវិហារយូរៗម្ដងភ្លេចខ្លួន យើងជាក្រុមមួយយ៉ាងពិសេសដែលអធិដ្ឋានជានិច្ចទាំងនៅក្នុងព្រះវិហារ និងនៅតាមផ្ទះរបស់យើងដែរ។ ឲ្យថែរក្សាការអធិដ្ឋានរបស់យើង ដើម្បីទទួលកម្លាំងពីព្រះបេះដូងរបស់ព្រះយេស៊ូផ្ទាល់។

ពេលយើងធ្វើខួប២០ឆ្នាំ សង្ឃឹមថាយើងមានគ្នាច្រើនជានេះគុណនឹងពីរ និងយើងមានក្រុមបេះដូងព្រះយេស៊ូកម្ពុជាពិតមែន។ ឲ្យបងប្អូនវៀតណាម ដែលរស់នៅលើកទឹកដីប្រទេសកម្ពុជា ធ្វើជាស្ពានដើម្បីឲ្យបងប្អូនខ្មែរនៅថ្ងៃអនាគតមានក្រុមបេះដូងព្រះយេស៊ូដែរ។

សូមព្រះជាម្ចាស់ប្រទានពរ ដល់ក្រុមបេះដូងព្រះយេស៊ូទៅជាកម្លាំងមួយ ដើម្បីបង្ហាញធម៌មេត្តាករុណានៅក្នុងព្រះសហគមន៍នីមួយៗ និងដើម្បីឲ្យវត្តមានរបស់ព្រះយេស៊ូណែនាំឲ្យព្រះរាជ្យរបស់ព្រហាជាម្ចាស់យាងមកឆាប់ៗ។

ជយោ ក្រុមបេះដូងព្រះយេស៊ូកម្ពុជា!